00876905

| |
|---|
| ឯកសារដើម |
| ORIGINAL DOCUMENT/DOCUMENT ORIGINAL |
| ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 08 / 01 / 2013 |
| ម៉ោង (Time/Heure) : 13:50 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN |

002/19-09-2007-ECCC/TC
E1/146

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ សុក្រ ទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១៣៣

រៀបចំដោយ: សែ គុណវុឌ្ឍី និង Matteo CRIPPA

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ គុណវុឌ្ឍី, លោក Matteo CRIPPA. |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក វ៉េង ហ៊ត, លោក Tarik ABDULHAK, លោក Keith RAYNOR. |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI. |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS (អវត្តមាន) |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE. |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក វ៉ែន ពៅ, លោកស្រី Christine MARTINEAU, លោក Madhev MOHAN, លោក គង់ ផល្លះ, លោកស្រី ទី ស្រ៊ីនណា |
| សាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី អោ រី (TCCP-105), លោក ចៅ នី (TCCP-187) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី ស្វ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា Eleanor DOYLE-MARKWICK. |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៥.១៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៤៥ | បញ្ចប់ម៉ោង៖ ១១.១០ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.១៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ២៥ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំទទួលស្គាល់មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី | អង្គជំនុំជម្រះ | ០៩.០៨ | ០៩.១១ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី អោ រី (TCCP-105) | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី | ០៩.១១<br>១០.០៤<br>១០.៣៥ | ១០.០៤<br>១០.៣៥<br>១០.៤០ |
| ការបង្ហាញអំពីសេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី អោរី (TCCP-105) | អង្គជំនុំជម្រះ | ១០.៤០ | ១០.៤៥ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី | អង្គជំនុំជម្រះ | ១១.១១ | ១១.១៥ |

| | | | |
|---|---|---|---|
| ចៅ នី (TCCP-187) | មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញា | ១១.១៥<br>១៤.០៨ | ១៤.០៧<br>១៤.៣៧ |
| សំណើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្ដី នួន ជា | ១២.១១ | ១២.១៥ |
| មេធាវីការពារក្ដី ខៀវ សំផន បានតាំងសំណួរអំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការសួរសំណួរផ្ទាល់ទៅជនជាប់ចោទ | មេធាវីការពារក្ដី ខៀវ សំផន | ១៤.៣៩ | ១៤.៥៨ |
| ការបង្ហាញអំពីសេចក្ដីថ្លែងទុក្ខសោករបស់ដើមបណ្ដឹង ចៅ នី (TCCP-187) | អង្គជំនុំជម្រះ | ១៤.៣៩ | ១៤.៥៨ |
| ការកត់សម្គាល់ទៅលើសេចក្ដីថ្លែងទុក្ខសោករបស់ដើមបណ្ដឹងរដ្ឋប្បវេណី លោក ចៅ នី (TCCP-187) | មេធាវីការពារក្ដី ខៀវ សំផន | ១៥.០០ | ១៥.១៤ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការស្នើសុំទទួលស្គាល់មេធាវីអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

មេធាវីនាំមុខតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី បានស្នើសុំអង្គជំនុំជម្រះឲ្យទទួលស្គាល់មេធាវីអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី លោក Mahdev MOHAN និងមេធាវីជាតិលោក គង់ ផល្លះ ដែលបានជូនដំណឹងមកអង្គជំនុំជម្រះរួចហើយ។ អង្គជំនុំជម្រះបានទទួលស្គាល់មេធាវីអន្តរជាតិថ្មី លោក Mahdev MOHAN តំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ០០២/០១នេះ។

**<u>ការបន្តតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី អោ រី (TCCP-105)</u>**

មេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបានបន្តតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី អោរី (TCCP-105)។ បន្ទាប់មកមេធាវីការពារក្ដី នួន ជា និងមេធាវីការពារក្ដី អៀង សារី បានតាំងសំណួរនិងបញ្ចប់ការតាំងសំណួរទៅដើមបណ្ដឹងរូបនេះ។ ជាចុងក្រោយ ដើមបណ្ដឹងរដ្ឋប្បវេណី អោ រី (TCCP-105) បានធ្វើសេចក្ដីថ្លែងអំពីទុក្ខសោក និងព្យសនកម្មដែលគាត់បានទទួលរងក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

00876908



**ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី (TCCP-187)**

ប្រធានអង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួនទៅដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងអត្តសញ្ញាណ បន្ទាប់មកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាបានតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**ការស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ**

ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់ បានលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី TCCP-105 និង TCCP-187។ ជនជាប់ចោទ នួន ជា តាមរយៈមេធាវីការពារក្តីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការសម្រាប់ដំណើរការសវនាការនៅពេលរសៀល បន្ទាប់មកមេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យគ្រូពេទ្យពិនិត្យសុខភាពលោក នួន ជា ក្នុងអំឡុងពេលសម្រាក ដោយបញ្ជាក់ថា តើគាត់អាចចូលរួមសវនាការបានដែរឬទេ។ អង្គជំនុំជម្រះយល់ព្រមតាមការស្នើសុំ និងអនុញ្ញាតិឱ្យលោក នួន ជា ចូលរួមតាមដានដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យគ្រូពេទ្យធ្វើការពិនិត្យសុខភាពរបស់ នួន ជា ហើយធ្វើរបាយការណ៍មកអង្គជំនុំជម្រះមុនសវនាការពេលរសៀលនេះ។

**មេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសួរសំណួរទៅជនជាប់ចោទ**

ដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 បានស្នើសុំមកអង្គជំនុំជម្រះក្នុងការតាំងសំណួរទៅជនជាប់ចោទ ខៀវ សំផន មេធាវីការពារក្តីឱ្យ ខៀវ សំផន បានលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិក្នុងការសួរសំណួរដោយផ្ទាល់ទៅជនជាប់ចោទក្នុងអំឡុងពេលធ្វើសេចក្តីថ្លែងអំពីទុក្ខសោករបស់ខ្លួននោះទេ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាបានលើកឡើងថា មិនមានការហាមប្រាមដូច្នេះទេ។ ជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់ថាគាត់រក្សាសិទ្ធិក្នុងការធ្វើការកត់សម្គាល់នានាទាក់ទងនឹងកថាខណ្ឌជាក់លាក់ណាមួយនៃដីកាដំណោះស្រាយនៅចុងបញ្ចប់នៃសវនាការនេះ ហើយនឹងពិចារណាថាតើគាត់គួរត្រូវឆ្លើយតបទៅនឹងសំណួរទាំងអស់នៅពេលដែលភស្តុតាងទាំងឡាយត្រូវបានលើកយកមកពិភាក្សាពេញលេញរួចហើយ។ ជនជាប់ចោទ ខៀវ សំផន បដិសេធមិនឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ។

**ការធ្វើសេចក្តីថ្លែងទុក្ខសោក របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី (TCCP-187)**

ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីថ្លែងទុក្ខសោកទាក់ទងនឹងការឈឺចាប់ និងព្យសនកម្មដែលគាត់បានទទួលរងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។ ដើមបណ្តឹងរដ្ឋប្បវេណីបានប្រើប្រាស់ឱកាសនេះក្នុងការស្នើសុំតាំងសំណួរទៅជនជាប់ចោទ ខៀវ សំផន។

**<u>ការកត់សម្គាល់របស់ភាគីអំពីការធ្វើសេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី</u>**

មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងការជំទាស់ពីរទាក់ទងនឹងសេចក្តីថ្លែងអំពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ទី១-អត្ថន័យនៅក្នុងសេចក្តីថ្លែងនោះបានចាកឆ្ងាយពីអង្គហេតុដែលត្រូវធ្វើការដេញដោលនៅក្នុងសំណុំរឿងលេខ០០២/០១។ ទី២-សិទ្ធិរបស់ជនជាប់ចោទត្រូវបានរំលោភ ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតិឲ្យបង្ហាញភស្តុតាងដាក់បន្ទុក នៅពេលដែលមេធាវីការពារក្តីខៀវ សំផន មិនមានឱកាសក្នុងការឆ្លើយតបទៅនឹងការថ្លែងទុក្ខសោកនោះ។

អង្គជំនុំជម្រះបានឆ្លើយតបថាសេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនពូរបស់គាត់បន្ទាប់ពីការជម្លៀសទីក្រុងភ្នំពេញគឺស្ថិតនៅក្នុងវិសាលភាពនៃការធ្វើសវនាការក្នុងសំណុំរឿងលេខ០០២/០១។ អង្គជំនុំជម្រះក៏បានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការតាំងសំណួរ ហើយជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/3967 | D22/3455 | 00565891-00565898 00860728-00860734 00861202-00861210 | ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អោ រី OR Ry 09-VU-03804<br>Civil party application of OR Ry 09-VU-03804<br>Demande de constitution de partie civile de RO Ry 09-VU-03804 | P | 00565899 | 00660730 | 00861206 |
| E3/3968 | D22/3455a | 00586120-00586122 00858556-00858558 | ឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី<br>Supplementary information of civil party applicant/Document d'information supplementaire de partie civile | P | 00586120 | 00858556 | |
| E3/3969 | D22/253 | 00421593-00421601 00478475-00478480 00858930-00858938 | ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក ចៅ នី<br>Civil party application of CHAU Ny<br>Constitution de partie civile de CHAO Ny | P | 00421599 | 00478480 | 00858937 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតិឱ្យជនជាប់ចោទ នួន ជា (១២.១៤) ចូលរួមដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួន (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនដើមបណ្តឹងរដ្ឋប្បវេណី អោ រី (TCCP-105) និង ថៅ នី (TCCP-187) ត្រឡប់ទៅកាន់គេហដ្ឋានរបស់ពួកគាត់វិញ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំគាត់មកកាន់បន្ទប់សវនាការនៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ ។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ អង្គារ៍ ទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ វេលាម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ [illegible] Matteo CRIPPA